# ការលើកកម្ពស់សហប្រតិបត្តិការក្នុងតំបន់ ដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា[1]

វេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

សង្ខេបគោលនយោបាយ 2013, លេខ 03 *

## សេចក្ដីផ្ដើម

គ្មានប្រទេសណាមួយអាចរក្សាកំណើនសេដ្ឋកិច្ចខ្ពស់បានយូរអង្វែង ដោយមិនបានចូលរួមសកម្មនៅក្នុង ក្របខ័ណ្ឌផ្សេងៗនៃសហប្រតិបត្តិការក្នុងតំបន់ និងក្នុងពិភពលោកឡើយ។ សហប្រតិបត្តិការក្នុងតំបន់ជះឥទ្ធិពលទៅលើកំណើនតាមបែបបទជាច្រើន។ វាបើកផ្លូវឲ្យប្រទេសនោះ អាចទាញផលចំណេញពីឧត្តមភាពប្រៀបធៀប បង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន សម្រួលដល់ការទទួលបានចំណេះដឹងនិងបច្ចេកវិទ្យាពីបរទេស ដែលនឹងជួយបង្កើនផលិតភាព ទាក់ទាញវិនិយោគបានកាន់តែច្រើន ជំរុញការប្រកួតប្រជែង និងកែលំអសមត្ថភាពប្រកួតប្រជែង។ ក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅនេះ កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្ដូរសេដ្ឋកិច្ចដ៏ជ្រាលជ្រៅចេញពី របបពាណិជ្ជកម្មគ្រប់គ្រងដោយរដ្ឋ ទៅជារបបពាណិជ្ជកម្មតម្រង់ទិសទៅទីផ្សារខាងក្រៅ។ នាពេលបច្ចុប្បន្នដែលសេដ្ឋកិច្ចកាន់តែមានលក្ខណៈសេរី និងពឹងពាក់គ្នាខ្លាំងនោះ បញ្ហាប្រឈមធំ គឺ តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យសហប្រតិបត្តិការក្នុងតំបន់ជួយជំរុញដល់កំណើនសេដ្ឋកិច្ច។ អត្ថបទនេះព្យាយាមឆ្លើយនឹងសំណួរសំខាន់ពីរ៖ (១) ហេតុអ្វីសហប្រតិបត្តិការក្នុងតំបន សំខាន់បំផុតសម្រាប់គន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា? (២) តើត្រូវមានគោលនយោបាយអ្វីខ្លះ ដើម្បីឲ្យកម្ពុជាអាចទាញយកអត្ថប្រយោជន៍បាន ច្រើនបំផុតពីសហប្រតិបត្តិការក្នុងតំបន់?

## ហេតុអ្វីសហប្រតិបត្តិការក្នុងតំបន់សំខាន់បំផុត សម្រាប់គន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា?

សហប្រតិបត្តិការក្នុងតំបន់ មានសារៈសំខាន់ណាស់សម្រាប់យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចរយៈពេលវែងរបស់កម្ពុជា ដោយសារហេតុផលធំៗ ៣ គឺ៖ (១)ទិដ្ឋភាពនៃសេដ្ឋកិច្ចអន្តរជាតិកំពុងផ្លាស់ប្ដូរលឿនណាស់ ដែលទាមទារឲ្យមានការកែសម្រួលគោលនយោបាយជាប្រចាំ ដើម្បីដោះស្រាយបញ្ហាប្រឈមកំពុងផុសឡើងនានា (២) សមាហរណកម្មសេដ្ឋកិច្ច ដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការរីកលូតលាស់នាពេលកន្លងមក និង (៣) កម្ពុជាជាចំណុចស្នូលនៃក្របខ័ណ្ឌសហប្រតិបត្តិការផ្សេងៗក្នុងតំបន់។

## ការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចអន្តរជាតិ

ក្នុងមួយទសវត្សរ៍កន្លងទៅ អភិបាលកិច្ចសេដ្ឋកិច្ចអន្តរជាតិ បានប្រែប្រួលគួរឲ្យកត់សម្គាល់ ជាពិសេសកំណើនស្មុកស្មាញនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ (RTAs) និងការផុសឡើងនៃខ្សែចង្វាក់ផ្គត់ផ្គង់សកល (GSCs)។ ទោះបីជាពាណិជ្ជកម្មពហុភាគីដែលគាំទ្រដោយវិធាននានារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅតែជាសសរស្តម្ភដ៏សំខាន់មួយនៃប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ក៏ RTAs នៅតែកើនស្មុកស្មុះដែលអាចជំពាក់គ្នាស្មុគស្មាញដូច "មីមួយចាន" (spaghetti bowl)។ នៅត្រឹមខែមករា ២០១៣ WTO បានទទួលសេចក្ដីប្រកាស RTAs ចំនួន ៥៤៦ ហើយក្នុងនោះមាន ៣៥៤ RTAs បានចូលជាធរមាន និងគ្របដណ្ដប់លើជាង ៥០% នៃពាណិជ្ជកម្មពិភពលោក។ តំបន់អាស៊ីបូព៌ា មានសន្ទុះខ្លាំងណាស់ក្នុងកិច្ចព្រមព្រៀង RTAs មានច្រើនស្រទាប់។ នៅត្រឹមខែមីនា ២០១៣ ប្រទេសនានាក្នុងតំបន់នេះបានចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ជាលក្ខណៈទ្វេភាគី អនុតំបន់ តំបន់ និងពិភពលោក សរុបទាំងអស់ ១៤៣ ហើយកំពុងចរចារៀបចំ FTAs[2] ចំនួន ៨៤ ថែមទៀត ដែលបង្កើតបានជា "មីមួយចានរបស់អាស៊ី"។ អាស៊ានជាចំណុចស្នូល និងជាកាតាលីករនៃកិច្ចប្រឹងប្រែងនានានៅតំបន់អាស៊ី។ក្រៅពីការប្ដេជ្ញាចិត្តកសាងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឲ្យបាននៅឆ្នាំ២០១៥នោះ អាស៊ានក៏មាន ការព្រមព្រៀងផ្នែកគោលនយោបាយពាណិជ្ជកម្មជាច្រើន ជាមួយដៃគូនានានៅអាស៊ីដែលពីដំបូងគឺ អាស៊ានបូកមួយ បន្ទាប់មក អាស៊ានបូកបី ហើយនិង អាស៊ានបូកប្រាំមួយនាពេលថ្មីៗនេះទៀត។ ក្នុងកិច្ចប្រជុំកំពូលតំបន់អាស៊ីបូព៌ា ឆ្នាំ២០១២ ថ្នាក់ដឹកនាំទាំង ១៦ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក បានចាប់អនុវត្តភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់អាស៊ាន ដើម្បីបន្សីគ្នាជាមួយស្ថាបត្យកម្មពាណិជ្ជកម្មក្នុងតំបន់ ដែលមានស្រាប់។ កត្តានេះនឹងជួយពង្រឹងតួនាទីស្នូលរបស់អាស៊ាន នៅក្នុងស្ថាបត្យកម្មសេដ្ឋកិច្ចកម្រិតតំបន់ដែលកំពុងផុសឡើង និងជួយបន្សី ភាពខុសប្លែកគ្នាក្នុងចំណងទាក់ទង "មីមួយចាន" រវាងកិច្ចព្រមព្រៀង FTAs ផ្សេងៗរបស់អាស៊ាន។

ខ្សែចង្វាក់ផ្គត់ផ្គង់សកល ដែលជាការបំបែកដំណើរការផលិតកម្មទៅជាដំណាក់កាលដាច់ៗគ្នាពីក្រោមទៅលើ និងអនុវត្តនៅក្នុងប្រទេសខុសៗគ្នានោះ កាន់តែឃើញមានជាទូទៅហើយ។ ការផ្លាស់ប្ដូរទីតាំងផលិតកម្ម ត្រូវបានជំរុញឡើងដោយ (១)ការរីកចម្រើនឆាប់រហ័សផ្នែកបច្ចេកវិទ្យាផលិតកម្ម ដែលជួយឲ្យឧស្សាហកម្មអាចបែងចែកខ្សែចង្វាក់តម្លៃ ទៅជាសមាសភាពតូចៗងាយស្រួលសម្រាប់ការផ្លាស់ទី (២)ការអនុវត្តបែបថ្មីក្នុងការប្រាស្រ័យទាក់ទង និងដឹកជញ្ជូន បានកាត់បន្ថយចម្ងាយផ្លូវ និងបង្កើតចំណងទាក់ទងផ្នែកសេវាកម្ម ដែលជួយផ្សំបញ្ចូលគ្នានូវចំណែកផ្សេងៗនៃដំណើរការផលិតកម្ម ឲ្យមានលក្ខណៈទាន់ពេលល្អ និងមានប្រសិទ្ធភាពផ្នែកចំណាយ និង (៣)កំណែទម្រង់គោលនយោបាយទាំងនៅក្នុងប្រទេសដើម និងក្នុងប្រទេសកំពុងដំណើរការខ្សែចង្វាក់ឧស្សាហកម្ម បានកាត់បន្ថយរបាំងផ្សេងៗចំពោះពាណិជ្ជកម្ម និងវិនិយោគ (Athukorala and Nasir 2012)។

---

[1] រៀបរៀងដោយលោក ហ៊ីង វុត្ថា អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងជាអ្នកសម្របសម្រួលក្រុមចំណាប់អារម្មណ៍ស្រាវជ្រាវ របស់ DRFស្ដីពី "កម្ពុជា និងតំបន់ជុំវិញ"។ អត្ថបទសង្ខេបគោលនយោបាយនេះ ដកស្រង់ចេញ ពីឯកសារពិភាក្សាលេខ ៨១ របស់ CDRI ដែលចងក្រងដោយលោក ហ៊ីង វុត្ថា ស្ដីពី "ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា"។

[2] ការិយាល័យសមាហរណកម្មក្នុងតំបន់អាស៊ី របស់ ADB។ http://aric.adb.org/ftatrends.php (accessed March 2013)

ហេតុអ្វី ស្ថានភាពសេដ្ឋកិច្ចអន្តរជាតិកំពុងផ្លាស់ប្តូរឆាប់រហ័សនេះ មានផលពាក់ព័ន្ធយ៉ាងសំខាន់ដល់ កំណើនសេដ្ឋកិច្ចនៅកម្ពុជា? ផលសំខាន់ទី១ គឺបទពិសោធន៍របស់ប្រទេសមានជោគជ័យក្នុងការនាំចេញកាលពីទសវត្សរ៍១៩៩០។ សេដ្ឋវិទូផ្នែកអភិវឌ្ឍន៍មានជំនឿមុតមាំថា ប្រទេសដែលអាចរក្សាចីរភាពកំណើនសេដ្ឋកិច្ច ត្រូវអនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហ និងផ្តោតលើការនាំចេញ។ ប្រទេសមានជោគជ័យភាគច្រើន បានទទួលអត្ថប្រយោជន៍ធំធេងពីសមាហរណកម្មពិភពលោក ដោយប្រើពាណិជ្ជកម្ម និងវិនិយោគ ជាសមាសធាតុស្នូលនៃកំណើនសេដ្ឋកិច្ច។ ក្រៅពីការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ កម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ធំធេងផងដែរ ពីកំណើនពាណិជ្ជកម្ម និងការចូលរួមក្នុងក្របខ័ណ្ឌសមាហរណកម្មក្នុងតំបន់ និងអនុតំបន់ផ្សេងៗ។ សមាហរណកម្មក្នុងតំបន់ក៏អាចលើកកម្ពស់ចំណងទាក់ទងជារូបវន្ត និងផ្តល់លទ្ធភាពកាន់តែធំក្នុងការទទួលបានទីផ្សារថ្មីៗ ធនធាន និងវិនិយោគ ដែលជួយជំរុញផលិតភាព ការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច។

ផលសំខាន់ទី២ ជាប់ទាក់ទងនឹងភាពចាំបាច់ត្រូវប្រើប្រាស់ក្របខ័ណ្ឌជាច្រើនសម្រាប់ ការធ្វើពិពិធកម្មការនាំចេញ កំណើនការនាំចេញ និងភាពប្រកួតប្រជែង។ ការសម្របខ្លួន តាមកិច្ចប្រឹងប្រែងដ៏សកម្មធ្វើសមាហរណកម្មក្នុងតំបន់ សំខាន់ខ្លាំងណាស់សម្រាប់កម្ពុជា ក្នុងការជំរុញពិពិធកម្ម និងភាពធន់ល្អនៃសេដ្ឋកិច្ច។ ការប្រមើលពី ការធ្វើសមាហរណកម្មទីផ្សារ និងបណ្តាញផលិតកម្មនៅអាស៊ីដែលលាតសន្ធឹងពីប្រទេសចិនភាគខាងត្បូងឆ្លងកាត់មហាអនុតំបន់មេគង្គទៅដល់តំបន់អាស៊ីអាគ្នេយ៍ទៀតនោះ បង្ហាញនូវឱកាសដ៏ធំធេងសម្រាប់វិនិយោគនិងពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យឯកជន ក៏ដូចជា កំណើន និងភាពរុងរឿងសេដ្ឋកិច្ចផងដែរ (Hing *et al.* 2013)។ កម្ពុជាមិនទាន់ក្លាយជាផ្នែកមួយនៃ ការបែងចែកគ្នាធ្វើ ផលិតកម្មដ៏សកម្មក្នុងរង្វង់តំបន់នោះទេ ប៉ុន្តែចលនាថ្មីមួយនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ពិភពលោករបស់អាស៊ី នឹងនាំមកនូវសករាជថ្មីពោរពេញដោយឱកាសល្អសម្រាប់បណ្តាប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើង។ ដោយសារកំណើនចំណាយផលិតកម្ម មានសហគ្រាសច្រើនណាស់ បានផ្លាស់ទីតាំងផលិតកម្មពីប្រទេសចិន ទៅកាន់ប្រទេសមានចំណាយផលិតកម្មទាបជាង ដើម្បីទាញយកឧត្តមភាពប្រៀបធៀបពី ចំណាយពលកម្មទាប កំណើនភាពពឹងផ្អែកគ្នាក្នុងរង្វង់តំបន់ និងលទ្ធភាពចូលទៅកាន់ទីផ្សារប្រទេសទី៣។ និន្នាការនេះស្តែងឲ្យ ឃើញច្បាស់ តាមការវិនិយោគរបស់សហគ្រាសជប៉ុនពីរ គឺ Minebea ដែលជាក្រុមហ៊ុនឈានមុខក្នុងពិភពលោកលើការផលិត ម៉ាស៊ីនខ្នាតមីក្រូ និង Sumitomo Electric ជាក្រុមហ៊ុនឈានមុខ ក្នុងការផលិតខ្សែអុបទិច ក្នុងគម្រោងបង្កើតកន្លែងផលិតកម្មទំនើបនៅកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់ទីផ្សារពិភពលោក។ ដោយសារខ្សែចង្វាក់ផ្គត់ផ្គង់ពិភពលោកត្រូវពឹងផ្អែកលើ ប្រព័ន្ធពាណិជ្ជកម្មបើកចំហដូច្នេះគោលនយោបាយឧស្សាហកម្មនិងពាណិជ្ជកម្មដើរតួនាទីសំខាន់បំផុតក្នុងការកំណត់ អត្រាការបោះទីតាំងរបស់ក្រុមហ៊ុននានានៅម្ពុជា។

## កំណែទម្រង់គោលនយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ចប្រកបដោយជោគជ័យ

កម្ពុជាបានផ្លាស់ប្តូរមានជោគជ័យ ពីសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំទៅជាសេដ្ឋកិច្ចបែបទីផ្សារ ដោយបានបោះបង់ចោលរបបសេដ្ឋកិច្ចមានរដ្ឋជាអ្នកគ្រប់គ្រងទាំងស្រុងលើថ្លៃ គុណភាពទំនិញ ការនាំចេញ និងការនាំចូល ហើយចាប់អនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មតម្រង់ទិសទៅខាងក្រៅ។ កម្ពុជាទទួលបានអត្ថប្រយោជន៍ពី គោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីតាមរូបភាពជាច្រើន ដូចជាការតភ្ជាប់សេដ្ឋកិច្ចរបស់ខ្លួនឲ្យកាន់តែស្អិតរមួត ជាមួយទីផ្សារក្នុងតំបន់ និងពិភពលោក និងការបង្កើនពាណិជ្ជកម្ម វិនិយោគ និងភាពប្រកួតប្រជែង។ កំណើនសេដ្ឋកិច្ចភាគច្រើនទទួលកម្លាំងជំរុញពី ៤វិស័យ គឺសម្លៀកបំពាក់និងស្បែកជើង ទេសចរណ៍ សំណង់ និងកសិកម្ម។ ការស្ទុះឡើងនៃវិស័យសម្លៀកបំពាក់ជាឧទាហរណ៍យ៉ាងច្បាស់ពី បែបបទដែលគោលនយោបាយពាណិជ្ជកម្មតម្រង់ទិសទៅខាងក្រៅ និងស្ថិតក្រោមប្រព័ន្ធពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក វាជះឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ច។ កំណើនឆាប់រហ័សនៃវិស័យទេសចរណ៍ ជាលទ្ធផលនៃគោលនយោបាយសំខាន់ៗ ដូចជា គោលនយោបាយបើកចំហជើងមេឃ ដែលចាប់អនុវត្តនៅចុងឆ្នាំ១៩៩៧ និង សហប្រតិបត្តិការផ្នែកគោលនយោបាយ ក្នុងតំបន់ក្នុងទម្រង់ជាយុទ្ធសាស្ត្រទេសចរណ៍មហាអនុតំបន់មេគង្គ ដែលសំដៅបង្កើតវិស័យទេសចរណ៍កម្រិតអនុតំបន់មួយ ឲ្យក្លាយជាក្បាលម៉ាស៊ីនចម្បងជំរុញការអភិវឌ្ឍ និង ផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន។

សេដ្ឋកិច្ចកម្ពុជាកាន់តែមានភាពបើកចំហនិងធ្វើសមាហរណកម្មខ្លាំងឡើង ហើយលក្ខណៈនេះជាបុរេលក្ខខណ្ឌដ៏ចាំបាច់មួយសម្រាប់កំណើនប្រកបដោយចីរភាព ព្រោះវាជួយបង្កើនវិនិយោគ បច្ចេកវិទ្យា ចំណេះដឹង និងផលិតភាព។ កម្ពុជាកំពុងចូលរួមសកម្មក្នុងមហាអនុតំបន់មេគង្គ យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចមេគង្គ- Ayeyawady-Chao Phraya (ACMECS), សមាគមប្រជាជាតិអាគ្នេយ៍ (អាស៊ាន) និងគម្រោងផ្តួចផ្តើមដោយអាស៊ានជាច្រើនទៀត ដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន, តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន, តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ, តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន, និងគំនិតផ្តួចផ្តើមអាស៊ានបូកបី។ យុទ្ធសាស្ត្រទាំងនេះផ្តល់នូវ មូលដ្ឋានដ៏ល្អមួយសម្រាប់ កំណត់នូវកំណែទម្រង់គោលនយោបាយបន្តទៀត និងពង្រឹងសមាហរណកម្មជាមួយសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។

មានមតិរិះគន់ខ្លះដែលផ្អែកលើការវិភាគហេតុការណ៍មុនសមាហរណកម្មបានរែកញែកថាកម្ពុជាគួរពន្យាពេលចូលរួមក្នុងប្លុកសេដ្ឋកិច្ចតំបន់រហូតដល់ពេលបានរៀបចំខ្លួនរួចរាល់លើផ្នែក លក្ខខណ្ឌសេដ្ឋកិច្ច និងសមត្ថភាព ប៉ុន្តែបើផ្អែកលើ វិធីសាស្ត្រវិភាគហេតុការណ៍ក្រោយសមាហរណកម្មវិញ គេអាចរែកញែកផ្ទុយពីនេះ។ កម្ពុជាមិនគ្រាន់តែជា ចំណែកមួយនៃនិន្នាការដ៏មានសន្ទុះនៃចន្លោះអនុតំបន់និយម តំបន់និយម និងសកលនិយមប៉ុណ្ណោះទេ ប៉ុន្តែសមាជិកភាពរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌផ្សេងៗនៃ សហប្រតិបត្តិការពាណិជ្ជកម្មច្រើនស្រទាប់ បានផ្តល់នូវបទពិសោធន៍ដ៏មានប្រយោជន៍ ដែលរៀនសូត្របានពីការអនុវត្តផ្ទាល់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ និងកំណែទម្រង់ក្នុងស្រុក។ សំខាន់បំផុត កម្ពុជាកំពុងទទួលបានគោលនយោបាយក្រៅប្រទេសប្រកបដោយមិត្តភាព និងសហប្រតិបត្តិការ ព្រមទាំងកេរ្តិ៍ឈ្មោះល្អនៅក្នុងវេទិកាតំបន់ និងពិភពលោក។ អ្នកវិភាគភាគច្រើនយល់ស្របថា សមាហរណកម្មអាស៊ានជាធាតុផ្សំមួយ និងមិនមែនជាឧបសគ្គមួយទេ ក្នុងការកសាងភាពជាដៃគូផ្នែកសេដ្ឋកិច្ចកាន់តែស្មុគស្មាញ និងស៊ីជម្រៅ ដើម្បីការអភិវឌ្ឍពាណិជ្ជកម្ម ឧស្សាហូបនីយកម្ម និងកំណើនសេដ្ឋកិច្ចមានចីរភាព។

## សេដ្ឋកិច្ច និងទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជា

កម្ពុជាមានទីតាំងស្នូលនៅក្នុងមហាអនុតំបន់មេគង្គ, អាស៊ាន, អាស៊ានបូកបី, និងក្របខ័ណ្ឌក្នុងតំបន់ជាច្រើនទៀត។ ទីតាំងជាយុទ្ធសាស្ត្រនេះ ជាទ្រព្យសម្បត្តិដ៏ចម្បងមួយ។ កម្ពុជាទទួលបានអត្ថប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធ និង "ការតភ្ជាប់" ក្នុងមហាអនុតំបន់មេគង្គ ស្ពាន ផ្លូវទឹក និងកំពង់ផែ។ ទន្ទឹមនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង ក៏មានការរីកចម្រើនផ្នែក ហេដ្ឋារចនាសម្ព័ន្ធទន់ផងដែរ ដូចជា កំណែទម្រង់បទបញ្ញត្តិច្បាប់ និងការកសាងសមត្ថភាពមន្ត្រី និងទីភ្នាក់ងាររដ្ឋាភិបាល ដែលទទួលខុសត្រូវលើចលនាទំនិញ និងមនុស្សឆ្លងកាត់ព្រំដែន។ ការប្រមើលឃើញពីទីផ្សារនិង បណ្តាញ ផលិតកម្មអាស៊ានរួមគ្នាមួយ ដែលលាតសន្ធឹងពីប្រទេសចិនភាគខាងត្បូងឆ្លងកាត់បណ្តាប្រទេស GMS ទៅដល់តំបន់ឯទៀតនៃអាស៊ីអាគ្នេយ៍នោះ បានផ្តល់ឱកាសយ៉ាងច្រើនសម្រាប់កំណើនវិបុលភាព ការអភិវឌ្ឍវិស័យឯកជន និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ផលចំណេញនេះ

កាន់តែសំខាន់ឡើងទៀត ដោយសារការបង្កើនល្បឿនសមាហរណកម្ម និងការតភ្ជាប់ក្នុងមហាអនុតំបន់ មេគង្គ អាស៊ាន និងអាស៊ីបូព៌ា។

## អាទិភាពគោលនយោបាយ ដើម្បីទាញយកផលប្រយោជន៍បានច្រើនបំផុតពីកិច្ចសហប្រតិបត្តិការក្នុងតំបន់

អត្ថបទសង្ខេបគោលនយោបាយនេះបង្ហាញទស្សនៈថា សហប្រតិបត្តិការក្នុងតំបន់ជា លក្ខខណ្ឌដ៏ចាំបាច់សម្រាប់កំណើន ប៉ុន្តែមិនមែនជាលក្ខណៈគ្រប់គ្រាន់នោះទេ។ ខាងក្រោមនេះ ជាអាទិភាពគោលនយោបាយមួយចំនួន ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពី សហប្រតិបត្តិការក្នុងតំបន់សម្រាប់កំណើនសេដ្ឋកិច្ច។

## ការរក្សាបានការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងត្រឹមត្រូវ

ការរក្សាបរិយាកាសម៉ាក្រូសេដ្ឋកិច្ចឲ្យមានស្ថិរភាព និងធន់ទ្រាំល្អនឹងវិបត្តិ ជាកត្តាសំខាន់បំផុតសម្រាប់ជោគជ័យនៃគោលនយោបាយជំរុញពាណិជ្ជកម្ម។ អាទិភាពគោលនយោបាយនានាសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចឲ្យបានត្រឹមត្រូវ រួមមាន ការរក្សាអតិផរណាឲ្យនៅក្រោម ៥%, ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់, ការកសាងភាពធន់ទ្រាំនៃវិស័យនាំចេញ, ការកែលំអការប្រមូលប្រាក់ចំណូល, និង ការពង្រឹងសេវាវិស័យហិរញ្ញវត្ថុ។

## ការកែលំអបរិយាកាសវិនិយោគ

បរិយាកាសលើកទឹកចិត្តឲ្យមានវិនិយោគទុន ត្រូវមានកត្តារួមផ្សំមួយចំនួន ដូចជា ភាពច្បាស់លាស់ក្នុងកម្រិតណាមួយខាងម៉ាក្រូសេដ្ឋកិច្ច, គុណភាពនិងលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ, បទបញ្ញត្តិរដ្ឋាភិបាល, លក្ខណៈនៃការយកពន្ធ, លទ្ធភាពទទួលបាននិងតម្លៃនៃហិរញ្ញប្បទានសម្រាប់ក្រុមហ៊ុននានា, លទ្ធភាពប្រើប្រាស់ តម្លៃ និងគុណភាពនៃកត្តាផលិតកម្ម, កម្រិតដែលរដ្ឋាភិបាល អាចញ៉ាំងឲ្យមានការប្រកួតប្រជែងដោយស្មើភាពសម្រាប់ក្រុមហ៊ុននានា, អភិបាលកិច្ចនិងអំពើពុករលួយ, និង បញ្ហាសន្តិសុខ។ អាទិភាពគោលនយោបាយបន្ទាន់ៗដើម្បីបំបាត់ភាពទន់ខ្សោយនៃបរិយាកាសវិនិយោគ រួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធ, ការតម្រឹម និងធ្វើឲ្យ នីតិវិធីគយមានលក្ខណៈសាមញ្ញជាងមុន, ការបង្កើនប្រសិទ្ធភាពការផ្គត់ផ្គង់, វិនិយោគលើការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព។ កិច្ចដំណើរការតំបន់សេដ្ឋកិច្ចពិសេសឲ្យកាន់តែស៊ីជម្រៅ ក៏ជួយលើកទឹកចិត្តដល់វិនិយោគដែរ ហើយអាចសម្រេចបានតាមរយៈហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខ្ពស់ច្រើនថែមទៀត, កិច្ចសហការផ្នែករដ្ឋបាលទាន់ពេលល្អ និងមានប្រសិទ្ធភាព, ទំនាក់ទំនងការងារអាចបត់បែន, លទ្ធភាពរកបានភ្លាមនូវកម្លាំងពលកម្មមានជំនាញទាប និងមានជំនាញខ្ពស់។

## ធ្វើវិនិយោគលើសមត្ថភាពមនុស្ស

ទីផ្សារពលកម្មកម្ពុជានាបច្ចុប្បន្ន អាចសម្គាល់បានតាមលក្ខណៈដែលកម្លាំងពលកម្មភាគច្រើនមានកម្រិតអប់រំទាប មុខជំនាញពលករមិនស៊ីគ្នានឹងការងារ និង កង្វះជំនាញតាមផ្នែកមួយចំនួន។ ផ្អែកតាមបទពិសោធន៍ប្រទេសមានជោគជ័យក្នុងការនាំចេញ កម្ពុជាត្រូវធ្វើវិនិយោគច្រើនៗទៅលើការបង្កើនសមត្ថភាព កម្រិតជំនាញ និងការអភិវឌ្ឍធនធានមនុស្ស។ គោលនយោបាយផ្នែកអប់រំគួរសង្កត់ធ្ងន់លើការអប់រំថ្នាក់បឋមសិក្សាជាសកល និងការកែលំអគុណភាពអប់រំនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គួរពង្រីកបន្ថែម និងផ្តោតលើជំនាញមានតម្រូវការបន្ទាន់ក្នុងទីផ្សារ។ ការអប់រំថ្នាក់ឧត្តមសិក្សា គួរផ្តោតលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតសាស្ត្រ។ ជម្រើសគោលនយោបាយជាអាទិភាព រួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធសាលារៀន ជាពិសេស នៅតំបន់ជនបទ ការបង្កើនការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការពលករមានជំនាញ ការកែលំអគុណភាពការបង្រៀន អភិបាលកិច្ចល្អនៃការអប់រំថ្នាក់ឧត្តមសិក្សា និង ការដាក់បញ្ចូលជាផ្លូវការនូវសមត្ថភាពផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ទៅក្នុងស្ថាប័នអប់រំជាន់ខ្ពស់។

## បន្សុីក្របខ័ណ្ឌសហប្រតិបត្តិការក្នុងតំបន់

បញ្ហាប្រឈមចំពោះមុខសម្រាប់កម្ពុជា គឺ ការធានាឲ្យវិស័យឯកជនអាចជួយសម្របសម្រួល អាចចូលដល់ និងអាចទាញយកអត្ថប្រយោជន៍ពីសហប្រតិបត្តិការក្នុងតំបន់។ កម្ពុជាត្រូវកែលំអរបៀបរបបស្ថាប័នរបស់ខ្លួន ដែលកន្លងមកបានរាំងដល់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្ម។ ការសម្របសម្រួល និងទំនាក់ទំនងរវាងទីភ្នាក់ងាររដ្ឋាភិបាលនានា ត្រូវតែច្បាស់លាស់ និងមានប្រសិទ្ធភាព។ ការកសាងសមត្ថភាពត្រូវផ្តល់ទៅឲ្យ បុគ្គលដែលមានតួនាទីនៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការផ្សេងៗ។ ចំណុចសំខាន់បំផុតនៅក្នុងនេះគឺ ការសម្របសម្រួល និងការបន្សុីចង្វាក់គ្នារវាងសហប្រតិបត្តិការអភិវឌ្ឍន៍ GMS អាស៊ាន អាស៊ី-បូព៌ា និង សមាហរណកម្មក្នុងតំបន់ដើម្បីញ៉ាំងឲ្យមាន ការយកចិត្តទុកដាក់លើកំណើនយូរអង្វែង និងការភ្ជិតគំលាតផ្នែកអភិវឌ្ឍន៍ ដោយមានការធ្វើវិនិយោគក្នុងតំបន់ទៅលើការអភិវឌ្ឍសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង។ពិតមែនតែសហប្រតិបត្តិការក្នុងតំបន់អាចជួយបើកចំហទីផ្សារ និងផ្តល់អត្ថប្រយោជន៍ដល់ផលិតករក្នុងស្រុក ជាពិសេសសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ប៉ុន្តែបញ្ហាដែលចោទរហូតមកគឺ ផលិតករខ្វះលទ្ធភាពទទួលបានព័ត៌មានស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម និង អត្ថប្រយោជន៍នៃកិច្ចព្រមព្រៀងទាំងនេះសម្រាប់ពួកគេ។ ទោះបី កម្ពុជាមានយន្តការថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋាភិបាល និងវិស័យឯកជនក្តី ក៏ការយល់ដឹង និងការចូលរួមពីវិស័យឯកជនក្នុងដំណើរការអាស៊ាន និង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)ជាទូទៅនៅអន់ខ្សោយនៅឡើយ។ចំណេះដឹងស្តីពីផលពាក់ព័ន្ធ និង អត្ថប្រយោជន៍នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅមានកម្រិតទាប ឬមិនបានស្មើគ្នាទេ។ ដូច្នេះត្រូវបង្កើនការយល់ដឹងថែមទៀតពីក្របខ័ណ្ឌសហប្រតិបត្តិការក្នុងតំបន់ ក្នុងចំណោមតួអង្គនៃវិស័យឯកជន និងលើកទឹកចិត្តពួកគេ ឲ្យចូលរួមក្នុងដំណើរការនៃសហប្រតិបត្តិការក្នុងតំបន់។

## ដោះស្រាយឧបសគ្គចំពោះគោលនយោបាយពាណិជ្ជកម្ម

a) *លើកកម្ពស់ប្រសិទ្ធភាពផ្នែកភស្តុភារ៖* កម្ពុជាស្ថិតក្នុងចំណោមប្រទេសមានសេវាកម្មភស្តុភារ ខ្វះប្រសិទ្ធភាពបំផុតក្នុងតំបន់។ ដំណើរការអន់ខ្សោយផ្នែកភស្តុភារ មកពីកត្តាជាច្រើន រួមមាន គុណភាពអន់ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ ប្រសិទ្ធភាពទាបក្នុងដំណើរការជម្រះឯកសារ អនុវត្តដោយមន្ត្រីគយ និងភ្នាក់ងារត្រួតពិនិត្យនៅច្រកព្រំដែន ព្រមទាំងសមត្ថភាព និងគុណភាពទាបនៃសេវាភស្តុភារ។ អន្តរាគមន៍គោលនយោបាយ អាចមានតាំងពីការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹងពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម រហូតដល់ ការគ្រប់គ្រងព្រំដែនឲ្យប្រសើរ ជាអាទិ៍ កំណែទម្រង់និងទំនើបកម្មបែបបទគយ ការចែកចាយព័ត៌មានឲ្យបានកាន់តែទូលំទូលាយ ការប្រកួតប្រជែងកាន់តែច្រើនក្នុងសេវាដឹកជញ្ជូនទំនិញតាមផ្លូវគោក ទឹក និងអាកាស និងលទ្ធភាពទទួលបានព័ត៌មានភ្លាមៗស្តីពីកិច្ចព្រមព្រៀងដឹកទំនិញឆ្លងកាត់ព្រំដែន។

b) *ធ្វើឲ្យនីតិវិធីគយមានលក្ខណៈសាមញ្ញជាងមុន៖* ទម្រង់បែបបទពន្ធគយ ដែលរួមមាន ការងារក្រដាសស្នាម ការពិនិត្យយល់ព្រមបទបញ្ញត្តិ និងប្រាក់កម្រៃ ជាឧបសគ្គចម្បងបំផុតបីដែលរាំងដល់ការនាំចេញ (World Bank 2009; ADB 2012)។ ដំណើរការនាំចូល និងនាំចេញមិនមានប្រសិទ្ធភាពនេះ ជះឥទ្ធិពលដោយផ្ទាល់ ដល់បន្ទុកចំណាយពាណិជ្ជកម្ម ផលិតភាព កត្តាផលិតកម្ម

សរុប និងភាពប្រកួតប្រជែង។ កម្ពុជាត្រូវធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយផ្សេងៗ ដើម្បីសម្រួលលើឧបសគ្គចម្បងៗចំពោះវិស័យឯកជន ជាពិសេសការធ្វើស្តង់ដារូបនីយកម្ម និងការធ្វើឲ្យសាមញ្ញនូវដំណើរការជម្រះឯកសារគយ និង ពាណិជ្ជកម្ម ការសម្របសម្រួលក្នុងចំណោមស្ថាប័នជួយសម្រួលផ្នែកពាណិជ្ជកម្មនិងដឹកជញ្ជូន និងលទ្ធភាពទទួលបានព័ត៌មានស្តីពី នីតិវិធីនាំចេញ បទបញ្ញត្តិ និងប្រាក់កម្រៃផ្សេងៗ។

c) *កែលំអសេវាផ្តល់ព័ត៌មានពីទីផ្សារនាំចេញ៖* កង្វះចំណេះដឹងពីនីតិវិធីនាំចេញនិងទីផ្សារនាំចេញរាំងស្ទះដល់សហគ្រាសក្នុងការប្រើប្រាស់ឲ្យបានពេញលេញនូវ ឱកាសផុសចេញពីសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងពិភពលោក (WTO 2011)។ ពិនិត្យតាមតួនាទីនៃបណ្តាអង្គការជំរុញពាណិជ្ជកម្ម ក្នុងការលុបបំបាត់បញ្ហាទទួលបានព័ត៌មានមិនដូចគ្នានោះ ការពង្រឹងតួនាទីរបស់ នាយកដ្ឋានលើកកម្ពស់ពាណិជ្ជកម្ម (TPD) ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជំរុញការនាំចេញ គឺជាសកម្មភាពដ៏ត្រឹមត្រូវ។ វិធានការជាអាទិភាពក្នុងរយៈពេលខ្លីគួរផ្តោតលើការផ្តល់ការគាំទ្រ និងព័ត៌មានដែលក្រុមហ៊ុននាំចេញត្រូវការ ជាពិសេសក្នុងការអភិវឌ្ឍផលិតផលនិងទីផ្សារ និងសេវាផ្តល់ព័ត៌មានពីទីផ្សារ។ សហប្រតិបត្តិការនិងជំនួយគាំទ្របានពីដៃគូអភិវឌ្ឍន៍នានា អាចមានប្រយោជន៍ក្នុងដំណាក់កាលដំបូង នៃកំណែទម្រង់ ព្រោះវាអាចជួយជំរុញ របៀបរបបអនុវត្តល្អ និងការរៀបចំប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែ ជំនួយគាំទ្របែបនេះគួរមានលក្ខណៈបណ្តោះអាសន្ន ហើយត្រូវបន្តដំណើរការដោយប្រើធនធានក្នុងស្រុកតាមរយៈ ការផ្តល់ថវិកាទាំងស្រុងពីរដ្ឋាភិបាល ឬការគួបផ្សំគ្នារវាងថវិកាពីរដ្ឋាភិបាល នឹងការបង់ថ្លៃសេវា។សមាសធាតុសំខាន់មួយទៀតក្នុងការពង្រឹង TPD គឺការធានាគុណភាពបុគ្គលិក តាមរយៈការកសាងសមត្ថភាពជាប្រចាំ និងការជ្រើសរើសបុគ្គលិកមានទេពកោសល្យ និងបទពិសោធន៍ផ្នែកពាណិជ្ជកម្ម។ វិធានការផ្នែកគោលនយោបាយគួរផ្តោតផងដែរលើ ការកសាងបណ្តាញពាណិជ្ជកម្មក្នុងស្រុក (រដ្ឋាភិបាល វិស័យឯកជន និងវិនិយោគិន) និងបណ្តាញក្រៅប្រទេស (រដ្ឋាភិបាល បរទេស អ្នកទិញ និងវិនិយោគិនអន្តរជាតិ) និងការកែលំអប្រព័ន្ធផ្តល់ព័ត៌មាន។

d) *ជំរុញការអនុវត្តតាមស្តង់ដារ៖* កម្ពុជាបានជួបបញ្ហាប្រឈមធំៗណាស់ក្នុងការអនុវត្តតាមស្តង់ដារបច្ចេកទេសរបស់ប្រទេសនាំចូល។ ការត្រួតពិនិត្យ និងពង្រឹងអនុវត្តន៍តាមស្តង់ដារ បានជួបឧបសគ្គធ្ងន់ធ្ងរ ជាអាទិ៍ ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិអន់ខ្សោយ ការសម្របសម្រួលអន់ខ្សោយ និងការជាន់តួនាទីគ្នាក្នុងចំណោមភ្នាក់ងារផ្សេងៗ អវត្តមានការធ្វើតេស្តជាប្រព័ន្ធក្នុងមន្ទីរពិសោធន៍ដើម្បីជួយទ្រទ្រង់ដល់ការត្រួតពិនិត្យ ដោយសារធនធានមនុស្ស និងហិរញ្ញវត្ថុមានតិច កង្វះការពិនិត្យតាមដាន និងអធិការកិច្ចជាលក្ខណៈប្រព័ន្ធ និង ប្រព័ន្ធចេញលិខិតបញ្ជាក់ដោយមិនធ្វើតេស្តផ្ទៀងផ្ទាត់ (FAO 2010)។ កំណែទម្រង់គ្រប់ជ្រុងជ្រោយនានា ក៏ត្រូវធ្វើដែរ ដើម្បីដោះស្រាយបញ្ហាចម្បងៗនៅក្នុងប្រព័ន្ធគ្រប់គ្រងស្តង់ដារ។ វិធានការដាក់ស្តែងនានា គួរផ្តោតលើការពង្រឹងក្របខ័ណ្ឌស្ថាប័ន ពិសេសទាក់ទងនឹងអាណត្តិ និងការសម្របសម្រួល, ការកសាងសមត្ថភាពផ្នែកគ្រប់គ្រង និងបច្ចេកទេស និងការបង្កើតអង្គភាពវាយតម្លៃរបស់កម្ពុជា ដែលទទួលស្គាល់ដោយទីភ្នាក់ងារផ្តល់ការទទួលស្គាល់ថ្នាក់អន្តរជាតិ។

## សេចក្តីសន្និដ្ឋាន

បទពិសោធន៍ពិភពលោកបង្ហាញថា គ្មានប្រទេសណាអាចរក្សាកំណើនសេដ្ឋកិច្ចខ្ពស់បានយូរ ដោយមិនធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោកឡើយ។ ចំណុចនេះគួរតែជាមធ្យោបាយឆ្ពោះទៅមុខសម្រាប់យុទ្ធសាស្ត្រកំណើន និងពាណិជ្ជកម្មរបស់កម្ពុជា។ សហប្រតិបត្តិការក្នុងតំបន់ ជាលក្ខខណ្ឌចាំបាច់មួយសម្រាប់គន្លងកំណើនសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែមិនមែនជាលក្ខខណ្ឌគ្រប់គ្រាន់នោះទេ។ សមាហរណកម្មទៅក្នុងតំបន់សេដ្ឋកិច្ចធំទូលាយជាងមុន អាចជួយពង្រឹងយុទ្ធសាស្ត្រកំណើនដ៏ភ្លឺស្វាងមួយ ប៉ុន្តែមិនអាចធានាជោគជ័យនៃយុទ្ធសាស្ត្រនោះឡើយ។ សមាសធាតុផ្សេងទៀតដែលជួយបន្ធូរបន្ថយឧបសគ្គរាំងស្ទះកំណើន និងដែលត្រូវមានជាចាំបាច់នោះ មានដូចជា ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អ, បរិយាកាសវិនិយោគ និងអាជីវកម្មមានលក្ខណៈស្និទ្ធស្នាល, ស្ថាប័នមានសមត្ថភាព, ការវិនិយោគលើធនធានមនុស្ស និងគ្រឿងសម្រួលការផ្នែកហេដ្ឋារចនាសម្ព័ន្ធ, និងគោលនយោបាយពាណិជ្ជកម្មមានប្រសិទ្ធភាព។

**សូមអានឯកសារយោងក្នុងអត្ថបទជាអង់គ្លេស**

### អំពីវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា

វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF) បានកកើតឡើងក្រោយពេលដែល មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាស្ថាប័នដៃគូទាំងអស់មួយ នៅខែកញ្ញា ឆ្នាំ២០០៧។ ទស្សនៈវិស័យរបស់ DRF គឺលើកកម្ពស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាឲ្យមានគុណភាពខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ព្រមទាំងមានគោលបំណងទ្រទ្រង់ និងពង្រឹងសមត្ថភាពរបស់សហគមន៍ស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា។ ដៃគូក្នុង DRF មាន វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI), សមាគមសេដ្ឋកិច្ចកម្ពុជា (CEA), វិទ្យាស្ថានសិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាល (LI), វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH), សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA), សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP), ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC), និង មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។

ក្នុង DRF ដំណាក់កាលទី២ ដោយបានទទួលជំនួយហិរញ្ញវត្ថុពី IDRC ដៃគូទាំងអស់ធ្វើការយ៉ាងសកម្ម ដើម្បីកសាងវប្បធម៌ស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវ ព្រមទាំងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមកតាមរយៈ សិក្ខាសាលា កិច្ចប្រជុំតុមូល ការបណ្តុះបណ្តាល និងពិភាក្សាតាមអ៊ីនធឺណែត (www.drfcambodia.net) ក្រោម ៦ ប្រធានបទ៖ កំណើនសម្រាប់គ្រប់គ្នា, អភិបាលកិច្ចធនធានធម្មជាតិ, គោលនយោបាយសង្គមកិច្ចស្តីពីការអប់រំ, គោលនយោបាយសង្គមកិច្ចស្តីពីសុខាភិបាល, ការអភិវឌ្ឍកសិកម្ម, និង ប្រទេសកម្ពុជានិងតំបន់ជុំវិញ។

### ភ្នាក់ងារជាដៃគូនៃ

សមាគមសេដ្ឋកិច្ចកម្ពុជា CAMBODIAN ECONOMIC ASSOCIATION
THE LEARNING INSTITUTE
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ Supreme National Economic Council
IDRC | CRDI


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ 56 ផ្លូវ 315, ខ័ណ្ឌទួលគោក ✉ ប្រអប់សំបុត្រលេខ 622, ភ្នំពេញ កម្ពុជា
☏ (855 23) 881 384/881 701/881 916/883 603 🖷 (855 23) 880 734
អ៊ីមែល: cdri@cdri.org.kh, គេហទំព័រ: www.cdri.org.kh